# សន្និសិទជាតិទិន្នន័យបើកទូលាយ
# ស្តីពីទិន្នន័យរដ្ឋាភិបាលបើកទូលាយដើម្បីការអភិវឌ្ឍប្រកបដោយបរិយាបន្ន

**កាលបរិច្ឆេទ៖** ថ្ងៃទី២៦-២៧ ខែមីនា ឆ្នាំ២០២៤

**ពេលវេលា៖** ៨:៣០ ព្រឹក ដល់ ៥:០០ ល្ងាច

**ទីតាំង៖** មជ្ឈមណ្ឌលនវានុវត្តន៍ឌីជីថល (CADT Innovation Center), រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

## សាវតា

យោងតាមក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ទិន្នន័យបានដើរតួនាទីយ៉ាងសំខាន់កាន់តែខ្លាំងឡើងនៅក្នុងអភិបាលកិច្ចសាធារណៈនៅកម្ពុជា ដោយសារហេតុផលមួយចំនួន។ ការប្តេជ្ញាចិត្តចំពោះកំណែទម្រង់ និងការបន្តកំណើនសេដ្ឋកិច្ច ត្រូវបានគេរំពឹងថានឹងធ្វើឱ្យប្រទេសកម្ពុជាក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។

ដំណើរការនៃការគ្រប់គ្រងរដ្ឋាភិបាលឌីជីថលនេះ ចាប់ផ្តើមជាមួយនឹងការបង្កើត និងការអនុម័តគោលនយោបាយចាំបាច់ និងការធ្វើបច្ចុប្បន្នភាពក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតដោយរាជរដ្ឋាភិបាលកម្ពុជា។ ដំណើរការនេះបន្តជាមួយនឹងការអភិវឌ្ឍស្តង់ដាររដ្ឋាភិបាលឌីជីថល និងរចនាបទ តាមរយៈគោលការណ៍ បទដ្ឋាន គំរូ ការវិវត្តន៍បច្ចេកវិទ្យា និងការអនុវត្តល្អបំផុតនៅកម្រិតជាតិ និងអន្តរជាតិ។ ទាំងនេះគឺជាមូលដ្ឋានគ្រឹះសម្រាប់ការបង្កើតរដ្ឋាភិបាលឌីជីថល ដែលប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងទ្រទ្រង់ដល់ការកសាង និងការរីកចម្រើននៃសេដ្ឋកិច្ច និងសង្គមឌីជីថលដ៏រឹងមាំ និងថាមវន្ត។

គោលនយោបាយទិន្នន័យបើកទូលាយ គឺជាគោលនយោបាយមួយក្នុងចំណោមគោលនយោបាយមួយចំនួនទៀតដែលរាជរដ្ឋាភិបាលកំពុងធ្វើការ និងប្រមូលធាតុចូល។ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលមានស្រាប់ គោលនយោបាយទិន្នន័យបើកទូលាយថ្មីនឹងកំណត់គោលការណ៍ ស្តង់ដារ អាជ្ញាប័ណ្ណ និងនីតិវិធីសម្រាប់ការបើកទូលាយ រក្សាទុក និងចែករំលែកទិន្នន័យរបស់រដ្ឋាភិបាលជាមួយស្ថាប័នសាធារណៈ វិស័យធុរកិច្ច និងបុគ្គល។ គោលបំណងចំបងបំផុតនៃទិន្នន័យបើកទូលាយ គឺដើម្បីបង្កើនតម្លាភាព យុត្តិធម៌ និងគណនេយ្យភាព ព្រមទាំងគុណភាពនៃសេវា ដែលការណ៍នេះការបង្កើនទំនុកចិត្តរបស់សាធារណៈជនចំពោះរដ្ឋាភិបាល លើកកម្ពស់ការស្រាវជ្រាវ និងការច្នៃប្រឌិតប្រកបដោយនិរន្តរភាព និងបរិយាបន្ន។[1] ទិន្នន័យបើកទូលាយនឹងអនុញ្ញាតឱ្យតួអង្គមិនមែនរដ្ឋចូលរួម ផ្តល់យោបល់ និងជំរុញរដ្ឋាភិបាលទទួលខុសត្រូវ បន្ថែមពីនេះ ទិន្នន័យបើកទូលាយនឹងជួយក្នុងការលើកកម្ពស់ការបើកទូលាយនៅក្នុងរដ្ឋាភិបាល។ ទោះជាយ៉ាងណាក៏ដោយ តួអង្គមិនមែនរដ្ឋនៅក្នុងប្រទេសកម្ពុជាបានត្រឹមតែសម្រេចបាននូវវឌ្ឍនភាពបន្តិចបន្តួចប៉ុណ្ណោះ[2] នៅក្នុងលក្ខខណ្ឌនៃការចូលប្រើទិន្នន័យ និងការប្រើប្រាស់ទិន្នន័យសម្រាប់គោលដៅគោលនយោបាយ។[3]

ដើម្បីសម្រេចនូវគោលដៅរួមនៃការផ្សារភ្ជាប់គម្លាតរវាងរដ្ឋាភិបាល និងតួអង្គមិនមែនរដ្ឋាភិបាលក្នុងកិច្ចសន្ទនាអំពីទិន្នន័យបើកទូលាយ **អង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី)** សហការជាមួយ **អង្គការមូលនិធិអាស៊ី** នឹងរៀបចំ **សន្និសិទទិន្នន័យបើកទូលាយជាតិនៅថ្ងៃទី២៦-២៧ ខែមីនា ឆ្នាំ២០២៤**។ បន្ថែមលើការលើកកម្ពស់កិច្ចសហប្រតិបត្តិការជាតិ និងតំបន់ និងកិច្ចខិតខំប្រឹងប្រែងទិន្នន័យទូលាយ យើងរំពឹងថាការចូលរួមដោយសេរី និងបរិយាបន្ននៅក្នុងព្រឹត្តិការណ៍នេះ នឹងបង្កើនការយល់ដឹងជាសាធារណៈ នៃ

[1] រាជរដ្ឋាភិបាលកម្ពុជា (RGC), "គោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២២-២០៣៥," ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២។

[2] អង្គការទិន្នន័យអំពីការអភិវឌ្ឍ, "របាយអង្កេតទិន្នន័យបើកទូលាយ," ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០។

[3] មូលនិធិអាស៊ី កម្មវិធីពន្លកចំណេះ, "អន្តរកាវីទិន្នន័យបើកចំហ សម្រាប់តួអង្គមិនមែនរដ្ឋនៅកម្ពុជា," ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៣។

ទិន្នន័យបើកទូលាយ និងការយកចិត្តទុកដាក់លើបញ្ហាប្រឈមនានា ដែលកម្ពុជាកំពុងជួបប្រទះក្នុងការទទួលយកទិន្នន័យបើកទូលាយ។

**សន្និសិទជាតិទិន្នន័យបើកទូលាយ ឆ្នាំ២០២៤** មានការគាំទ្រពីក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី តាមរយៈកម្មវិធី ពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត។

## គោលបំណងនៃសន្និសិទទិន្នន័យបើកទូលាយជាតិ

1. បង្កើនការយកចិត្តទុកដាក់ជាសាធារណៈនៃដំណើរការ និងឧបសគ្គក្នុងការទទួលយកទិន្នន័យបើកទូលាយនៅក្នុងប្រទេសកម្ពុជា និងតំបន់
2. ដើម្បីប្រមូលធាតុចូល និងសំណូមពរដើម្បីរួមចំណែកដល់សេចក្តីព្រាងគោលនយោបាយទិន្នន័យបើកទូលាយ និងបទប្បញ្ញត្តិអភិបាលកិច្ចទិន្នន័យ
3. ដើម្បីជំរុញកិច្ចផ្តួចផ្តើមតម្លាភាព និងគណនេយ្យភាពទិន្នន័យក្នុងវិស័យចម្រុះ
4. ដើម្បីពង្រឹងបណ្តាញទិន្នន័យបើកទូលាយនៅកម្ពុជា និងតំបន់

## អ្នកចូលរួម

សន្និសិទជាតិទិន្នន័យបើកទូលាយនឹងប្រមូលផ្តុំអ្នកចូលរួមយ៉ាងហោចណាស់ ៧៥នាក់ ដែលមានបទពិសោធន៍ផ្សេងៗគ្នា រួមមាន តំណាងរដ្ឋាភិបាល ក្រសួង អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ វិស័យឯកជន អ្នកស្រាវជ្រាវ និងអ្នកបង្កើតគោលនយោបាយ ក្រុមយុវជនជនជាតិដើមភាគតិច ជនមានពិការភាព ស្ត្រី និងក្រុមអ្នកស្រលាញ់ភេទដូចគ្នា (LGBTQI+)។

## អ្នករៀបចំ

**អង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី)** គឺជាវេទិកាទិន្នន័យបើកទូលាយឈានមុខគេក្នុងប្រទេសកម្ពុជា ដែលបង្កើតទិន្នន័យ និងព័ត៌មានបច្ចុប្បន្នភាព និងគួរឱ្យទុកចិត្តអំពីបញ្ហាសេដ្ឋកិច្ចសង្គម និងបរិស្ថាន បង្ហាញជាសាធារណៈក្នុងទម្រង់ជា "វេទិកាតែមួយ" ។ អង្គការអូឌីស៊ី លើកកម្ពស់ការប្រើប្រាស់ទិន្នន័យត្រឹមត្រូវសម្រាប់ដំណើរការធ្វើសេចក្តីសម្រេចចិត្តផ្អែកលើភស្តុតាង និងតម្លាភាព ឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាពរបស់ប្រទេស។ អស់រយៈពេលជប់ឆ្នាំកន្លងមកនេះ អង្គការអូឌីស៊ីបានធ្វើការយ៉ាងសកម្មដើម្បីបង្កើនបរិមាណទិន្នន័យសាធារណៈ លើកកម្ពស់ការយល់ដឹងជាសាធារណៈ និងកសាងសមត្ថភាពរបស់អ្នកពាក់ព័ន្ធ។ អង្គការអូឌីស៊ីប្រើប្រាស់ជំនាញរបស់ខ្លួនក្នុងវិស័យទិន្នន័យ និងបច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន (ICT) ការធ្វើផែនទី និង GIS សុវត្ថិភាពឌីជីថល និងការស្រាវជ្រាវ ដើម្បីចងក្រង វិភាគ និងផ្សព្វផ្សាយព័ត៌មានជាទម្រង់ឌីជីថលដែលងាយស្រួលប្រើ និងអាចចូលប្រើបាន។ សម្ភារៈដែលមាននៅលើវេទិកាអនឡាញរបស់អង្គការអូឌីស៊ី រួមមានសំណុំទិន្នន័យ ទំព័រប្រធានបទព័ត៌មាន ផែនទីអន្តរកម្ម ព័ត៌មាន និងឯកសារច្បាប់ ក្នុងចំណោមឯកសារផ្សេងៗទៀត។ អង្គការអូឌីស៊ី មិនផ្សព្វផ្សាយនូវទស្សនៈ របៀបវារៈ ឬការលំអៀងណាមួយ ក្រៅពីការផ្តល់ព័ត៌មានសត្យានុម័ត និងអំពីការអភិវឌ្ឍនៅប្រទេសកម្ពុជានោះទេ។

**អង្គការមូលនិធិអាស៊ី** កំពុងអនុវត្តកម្មវិធី ពន្លកចំណេះ៖ ទិន្នន័យ និងកិច្ចសន្ទនាសម្រាប់ការអភិវឌ្ឍន៍នៅកម្ពុជាចន្លោះខែកក្កដា ឆ្នាំ២០២៣ ដល់ខែមិថុនា ឆ្នាំ២០២៧ ដោយមានការគាំទ្រពីក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី។ គោលដៅនៃកម្មវិធី ពន្លកចំណេះទី២ គឺការសម្រេចចិត្តលើគោលនយោបាយសាធារណៈ ដោយផ្អែកលើភស្តុតាង និងត្រូវបានជូនដំណឹងដោយការសន្ទនារួម ត្រូវបានដាក់ឱ្យដំណើរការ និងក្លាយជាបទដ្ឋាននៅក្នុងប្រទេសកម្ពុជា។

## ការបដិសេធ

ព្រឹត្តិការណ៍នេះត្រូវបានផ្តល់មូលនិធិដោយក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី តាមរយៈកម្មវិធី ពន្លកចំនេះ៖ ទិន្នន័យ និងកិច្ចសន្ទនាសម្រាប់ការអភិវឌ្ឍនៅកម្ពុជា របស់អង្គការមូលនិធិអាស៊ី។ ទស្សនៈដែលបានលើកឡើងក្នុងព្រឹត្តិការណ៍នេះ គឺជាទស្សនៈរបស់វាគ្មិនទាំងស្រុង ហើយវាមិនមែនជាការឆ្លុះបញ្ចាំងពីទស្សនៈរបស់ រដ្ឋាភិបាលអូស្ត្រាលី អង្គមូលនិធិអាស៊ី ឬអង្គការទិន្នន័យអំពីការអភិវឌ្ឍនោះទេ។

| | |
|---|---|
| **សន្និសិទទិន្នន័យបើកទូលាយជាតិ ស្តីពីទិន្នន័យរដ្ឋាភិបាលបើកទូលាយដើម្បីការអភិវឌ្ឍប្រកបដោយបរិយាបន្ន**<br>មជ្ឈមណ្ឌលនវានុវត្តន៍ឌីជីថល (CADT Innovation Center), រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា | |
| **ថ្ងៃទី១: ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៤**<br>ទាំងតួអង្គរដ្ឋ និងមិនមែនរដ្ឋនឹងប្រើប្រាស់វេទិកានេះដើម្បីចូលរួមចំណែកទស្សនវិស័យរបស់ពួកគេ និងបញ្ហាប្រឈមសំខាន់ៗផ្សេងទៀត ដោយជំរុញឱ្យមានការសន្ទនាប្រកបដោយផលិតភាពលើការជំរុញគំនិតផ្តួចផ្តើមទិន្នន័យបើកទូលាយនៅក្នុងប្រទេស។ | |
| 8:00 – 8:30 | បើកចុះឈ្មោះអ្នកចូលរួម |
| 8:30 – 8:35 | គោរពភ្លេងជាតិ |
| 8:35 – 8:45 | **មតិស្វាគមន៍**<br>*អង្គការមូលនិធិអាស៊ី* |
| 8:45 – 8:55 | **សន្ទរកថាគន្លឹះ**<br>***ភ្នាក់ងារសេវ្គមព័ត៌មានជាតិ (NIA) នៃក្រសួងវិទ្យាសាស្ត្រ ព័ត៌មាន ទូរគមនាគមន៍ និងក្រសួងមហាផ្ទៃ និងសុវត្ថិភាពនៃសាធារណៈរដ្ឋកូរ៉េ [TBC]*** |
| 8:55 – 9:05 | **សុន្ទរកថា**<br>*តំណាងស្ថានទូតអូស្ត្រាលីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា [TBC]* |
| 9:00 – 9:15 | **សន្ទរកថាបើក**<br>*តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ [TBC]* |
| 9:15 – 9:30 | ថតរូបជាក្រុម និងសម្រាកអាហារសម្រន់<br>***ការតាំងបង្ហាញ កូនសៀវភៅទិន្នន័យបើកទូលាយ (ភាសាខ្មែរ) បកប្រែដោយ អូឌីស៊ី*** |
| 9:30 – 9:50 | **បទបង្ហាញទី១: របាយការណ៍អង្កេតទិន្នន័យបើកទូលាយ ២០២០**<br>របាយការណ៍អង្កេតនេះមានគោលបំណងស្វែងយល់អំពីតថភាពបច្ចុប្បន្ននៃធនធានទិន្នន័យបើកចំហនានាដែល មានស្រាប់ឬដែលកំពុងបង្កើតថ្មី ដែលពាក់ព័ន្ធនឹងដំណើរការគ្រប់គ្រងថវិការបស់គណៈកម្មាធិការជាតិសម្រាប់ការ អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងអំពីឱកាសនានាដើម្បីអភិវឌ្ឍវិស័យទិន្នន័យបើកចំហ នៅកម្ពុជា។ ការអង្កេតនេះផ្តោតសំខាន់លើការកំណត់រកធនធានទិន្នន័យបើកចំហដែលមានប្រភពពីស្ថាប័នរដ្ឋាភិ បាល សង្គមស៊ីវិល និងសាកលវិទ្យាល័យនានា។<br>***អង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី)*** |
| 9:50 – 9:55 | សំណួរ-ចម្លើយ |
| 9:55 – 10:25 | **បទបង្ហាញទី២: របាយការណ៍ស្រាវជ្រាវអំពី "អន្តរការីទិន្នន័យបើកចំហ សម្រាប់តួអង្គមិនមែនរដ្ឋនៅកម្ពុជា"**<br>ការសិក្សានេះស្វែងរកការវាយតម្លៃលទ្ធភាពនៃការបង្កើតអន្តរការីទិន្នន័យបើកចំហសម្រាប់តួអង្គមិនមែនរដ្ឋនៅក្នុងប្រទេសកម្ពុជា និងដើម្បីផ្តល់នូវការពិចារណាជាយុទ្ធសាស្ត្រសំខាន់ៗ។ ការសិក្សានេះក៏បង្កើតលើការសិក្សាថ្មីៗ ស្តីពីគោលនយោបាយសាធារណៈ និងវិស័យស្រាវជ្រាវនៅកម្ពុជាផងដែរ។<br>***អង្គការមូលនិធិអាស៊ី: ទិន្នន័យ និងកិច្ចសន្ទនាសម្រាប់ការអភិវឌ្ឍន៍នៅកម្ពុជា*** |
| 10:25 – 10:30 | សំណួរ-ចម្លើយ |
| 10:30 – 11:00 | **បទបង្ហាញទី៣: លទ្ធផលនៃការវាយតម្លៃផែនទីបង្ហាញផ្លូវទិន្នន័យបើកទូលាយនៅកម្ពុជា** |

| | |
|---|---|
| | របាយការណ៍វាយតម្លៃនេះត្រូវបានរៀបចំឡើងដើម្បីសិក្សាពីស្ថានភាពបច្ចុប្បន្ននៃទិន្នន័យបើកទូលាយ ពិនិត្យមើលការអនុវត្តរបស់ប្រទេសក្នុងតំបន់ និងពិភពលោក ប្រមូលធាតុចូលពីភាគីពាក់ព័ន្ធ វិភាគតំបន់អាទិភាពសម្រាប់ទិន្នន័យបើកទូលាយ និងរៀបចំរបាយការណ៍សម្រាប់ការបញ្ចូលសម្រាប់បង្កើតគោលនយោបាយទិន្នន័យបើកទូលាយ។ ក្រោមជំនួយបច្ចេកទេសរបស់សហភាពទូរគមនាគមន៍អាស៊ីប៉ាស៊ីហ្វិក (APT) សហការជាមួយភ្នាក់ងារសង្គមព័ត៌មានជាតិកូរ៉េ (NIA)។<br>*ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និង ទីភ្នាក់ងារសង្គមព័ត៌មានជាតិ (NIA) នៃក្រសួងវិទ្យាសាស្ត្រ ព័ត៌មាន ទូរគមនាគមន៍ និងក្រសួងមហាផ្ទៃ និងសុវត្ថិភាពនៃសាធារណៈរដ្ឋកូរ៉េ* |
| 11:00 – 11:05 | សំណួរ-ចម្លើយ |
| 11:05 – 12:05 | **កិច្ចសន្ទនា: ការរៀបចំគោលនយោបាយទិន្នន័យបើកទូលាយប្រកបដោយបរិយាបន្ននៅកម្ពុជា**<br>ដើម្បីស្វែងយល់ពីសេចក្តីព្រាងគោលនយោបាយទិន្នន័យបើកទូលាយរបស់កម្ពុជា និងច្បាប់ពាក់ព័ន្ធផ្សេងទៀត ក៏ដូចជាការប្រមូលផ្តុំធាតុចូលសំខាន់ៗ ដើម្បីជួយដល់រៀបចំគោលនយោបាយទិន្នន័យបើកទូលាយថ្មី និងអភិបាលកិច្ចទិន្នន័យនៅកម្ពុជាកាន់តែមានការចូលរួមនិងកាន់តែប្រសើរ។<br>**ការចូលរួមពីតំណាងភាគីពាក់ព័ន្ធសំខាន់ៗ រួមមាន៖**<br>1. ភ្នាក់ងាររដ្ឋាភិបាល<br>2. តួអង្គមិនមែនរដ្ឋាភិបាល<br>3. តំណាងនៃបណ្តាញទិន្នន័យបើកទូលាយក្នុងតំបន់<br>4. ជាពិសេសតំណាងក្រុមដែលងាយរងគ្រោះ<br>*សម្របសម្រួលដោយក្រុមការងារអូឌីស៊ី* |
| 12:05 – 12:15 | សំណួរ-ចម្លើយ |
| 12:15 – 13:30 | **អាហារថ្ងៃត្រង់រួមគ្នា** |
| 13:30 – 14:10 | **បទបង្ហាញទី៤: តួនាទីទិន្នន័យបើកទូលាយនៅក្នុងសារព័ត៌មាន**<br>*វាគ្មិន [TBC]* |
| 14:10 – 14:15 | សំណួរ-ចម្លើយ |
| 14:15 – 15:15 | **បទបង្ហាញទី៥: ការពណ៌នាសាច់រឿងដោយប្រើប្រាស់ទិន្នន័យ**<br>*អង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី)* |
| 15:15 – 15:30 | សំណួរ-ចម្លើយ |
| 15:30 – 15:45 | សម្រាកអាហារសម្រន់ |
| 15:45 – 16:45 | **កិច្ចពិភាក្សាជាក្រុម ១: ការចែករំលែកទិន្នន័យ និងការកសាងទំនុកចិត្តក្នុងចំណោមអ្នករួមចំណែកទិន្នន័យ**<br>ពិភាក្សាអំពីបញ្ហាប្រឈមដែលមានស្រាប់ដែលរារាំងការជឿទុកចិត្ត និងការរួមចំណែកទិន្នន័យកាន់តែទូលំទូលាយ ដូចជាការព្រួយបារម្ភអំពីឯកជនភាពទិន្នន័យ តម្លាភាព លទ្ធភាពទទួលបានសហគមន៍ក្នុងការចូលរួមប្រកបដោយអត្ថន័យ អត្ថប្រយោជន៍មិនស្មើគ្នា និងផលប៉ះពាល់សង្គម។<br>*អង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី) & អង្គការមូលនិធិអាស៊ី* |
| 16:45 – 17:00 | **សង្ខេបកិច្ចពិភាក្សាថ្ងៃទី១**<br>*អង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី)* |
| **ថ្ងៃទី២: ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៤**<br>ដើម្បីស្វែងយល់ ផ្លាស់ប្តូរបទពិសោធន៍ និងបង្កើនកិច្ចសហប្រតិបត្តិការទិន្នន័យលើវិស័យចម្រុះ ទាំងនៅក្នុងប្រទេសកម្ពុជា និងនៅថ្នាក់តំបន់។ | |
| 8:00 – 8:30 | **ការបើកចុះឈ្មោះអ្នកចូលរួម** |

| | |
|---|---|
| 8:30 – 9:00 | **សង្ខេបសកម្មភាពសំខាន់ៗថ្ងៃទីមួយ** |
| 9:00 – 12:00 | Breakout Room: **បទបង្ហាញពី គំនិតផ្តួចផ្តើម គេហទំព័រ ឬវេបផតថលទិន្នន័យរបស់ទីភ្នាក់ងាររដ្ឋាភិបាល តួអង្គមិនមែនរដ្ឋាភិបាល គ្រឹះស្ថានអប់រំ និងវិស័យឯកជននានា ដល់សាធារណជន និងតំណាងនៃបណ្តាញទិន្នន័យបើកទូលាយក្នុងតំបន់**<br>• **បន្ទប់ទី ១:** ទិន្នន័យរដ្ឋាភិបាលបើកទូលាយដើម្បីសេវាសាធារណៈកាន់តែប្រសើរ (៣ ប្រធានបទ)<br>• **បន្ទប់ទី ២:** ទិន្នន័យបើកទូលាយដើម្បីការអប់រំ (៣ ប្រធានបទ)<br>• **បន្ទប់ទី៣:** ទិន្នន័យបើកទូលាយដើម្បីការអភិវឌ្ឍដោយចីរភាព (៣ ប្រធានបទ) |
| 9:00 – 9:40 | Hackathon - Expert Talks & Workshops<br>ការពិភាក្សាខ្លីៗ និងសិក្ខាសាលាស្តីពីបច្ចេកទេសវិភាគទិន្នន័យជាក់លាក់ ការគិតក្នុងការរចនា និងជំនាញធ្វើបទបង្ហាញ ដើម្បីផ្តល់សិទ្ធិអំណាចដល់ក្រុម។<br>*គណៈកម្មាធិការ Hackathon* |
| 9:40 – 10:00 | សម្រាកអាហារសម្រន់ |
| 10:00 – 12:00 | Hacking Marathon<br>ក្រុមបន្តធ្វើការពេញមួយព្រឹកលើដំណោះស្រាយដែលជំរុញដោយទិន្នន័យរបស់ពួកគេ។ អ្នកណែនាំផ្តល់ការណែនាំ និងជំនួយបច្ចេកទេស។<br>*គណៈកម្មាធិការ Hackathon* |
| 12:00 – 13:30 | សម្រាកពិសារអាហារថ្ងៃត្រង់ |
| 13:30 – 14:30 | **បទបង្ហាញតាមបន្ទប់: ទំនាក់ទំនងនៃទិន្នន័យបើកទូលាយ និងការកសាងទំនុកចិត្ត**<br>• **បន្ទប់ទី១**: អាជីវកម្មប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវ<br>• **បន្ទប់ទី២៖** រួមបញ្ចូលការអភិវឌ្ឍន៍សង្គម និងការការពារសម្រាប់ទាំងអស់គ្នា |
| 14:30 – 15:45 | Hackathon Pitch – **បទបង្ហាញបញ្ចប់**<br>❖ ក្រុមនីមួយៗនឹងធ្វើបទបង្ហាញពីដំណោះស្រាយរបស់ពួកគេទៅកាន់គណៈកម្មាការដាក់ពិន្ទុ<br>❖ គណៈកម្មាធិការដាក់ពិន្ទុសួរសំណួរ និងផ្តល់មតិត្រលប់<br>*គណៈកម្មាធិការ Hackathon* |
| 15:45 – 16:00 | សម្រាកអាហារសម្រន់ |
| 16:00 – 16:40 | **ប្រកាសអ្នកឈ្នះ និងប្រគល់រង្វាន់** Hackathon<br>ជ័យលាភីនឹងទទួលរង្វាន់លើកទឹកចិត្តដើម្បីបន្តអនុវត្តសាកល្បងគំនិត ឬគម្រោងរបស់ពួកគេ ដើម្បីបង្កើតជាផលវិជ្ជមានដល់សង្គម។<br>*គណៈកម្មាធិការ Hackathon* |
| 16:40 – 17:00 | **មតិបូកសរុប និងបិទកម្មវិធី**<br>***អង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី)*** |

***បញ្ជាក់៖*** *អង្គការទិន្នន័យអំពីការអភិវឌ្ឍសូមរក្សាសិទ្ធិក្នុងការកែសម្រួលរបៀបវារៈក្នុងករណីចាំបាច់។*

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងទៅកាន់ **លោកស្រី ស៊ីវ វឌ្ឍនា** ប្រធានផ្នែកស្រាវជ្រាវនិងគ្រប់គ្រងមាតិកាគេហទំព័រ(អូឌីស៊ី) តាមទូរស័ព្ទ ឬ Telegram ៖ ០១២ ៣២៣ ០៤៥។